# ខ្មែរអើយចូរចាំ

ខ្មែរក្រោមស្រីប្រុស ទទួលរងគ្រោះ តើខុសរឿងអ្វី?
អស់ដីបាត់សិទ្ធិ រស់គ្មានសេរី ជួបតែទុក្ខភ័យ
គ្មានអ្វីពឹងពាក់។

ក្មេងតូចអាងយំ អ្នកក្រអាងសុំ អ្នកធំអាងស័ក្តិ
ជនពាលចិត្តបាប អាងកាប់អាងចាក់ អាងគុកច្រវ៉ាក់
ហៅអាងអបល័ក្ខណ៍។

ខ្មែរក្រោមក្មេងចាស់ ខ្លោចផ្សាខ្លាំងណាស់ ជូនក្តៅត្រជាក់
រស់រងទារុណ្ណ វែកពុនឧបសគ្គ រស់ប្រឹងបញ្ជាក់
ប្រាប់ដល់លោកីយ៍។

អនិច្ចាខ្មែរក្រោម រស់ក្នុងចង្កោម យួនចិត្តអប្រិយ៍
យួនខំបំបាត់ ខ្មែរម្ចាស់ទឹកដី ខ្មែរក្រោមប្រុសស្រី
ខំប្រឹងតស៊ូ។

ខ្មែរក្រោមខំក្រោក ខិតខំលៃលក រកល្បិចគិតគូរ
រំដោះជាតិខ្លួន ទោះឆាប់ឬយូរ តាំងចិត្តតស៊ូ
គង់បានសម្រេច។

បើខ្មែរគ្រប់គ្នា មានចិត្តរួញរា ខំប្រឹងតែខ្លាច
យួនវាបានដៃ ជាតិខ្មែរនិងក្ស័យ យួនពូជចង្រៃ
ខ្មែរអើយចាំទុក។

កូនមាន់ព្រាត់មេ មានទុក្ខកើនទ្វេ គ្មានមេនាំមុខ
ឯយ៉ាងណាមិញ ខ្មែរក្រោមមានទុក្ខ គ្មានម៉ែគ្មានពុក
មើលថែរក្សា។

ខ្មែរក្រោមចិត្តខ្លាំង នៅតែតតាំង ការពាររក្សា
មិនឲ្យបាត់បង់ សោះសូន្យឡើយណា អ្វីដែលដូនតា
ខ្មែរធ្លាប់មានមក។

ហុកសិបឆ្នាំប្លាយ ខ្មែរក្រោមខ្វល់ខ្វាយ រស់រងវិប្បយោគ
ខ្មែរទាំងតូចធំ ជួបតែទុក្ខសោក តាំងពីយូរមក
គ្មានគេមើលថែ។

កាលពីនៅស្រុក ពួកយួនគម្រក់ វាហៅខ្ញុំខ្មែរ
មកដល់ភ្នំពេញ ចូលក្រុងចោលស្រែ ទាស់តែជាតិខ្មែរ
ប្រែហៅខ្ញុំយួន

គិតមើលគ្រប់សព្វ ស្ទើរតែចង់ឡប់ ព្រោះកំណើតខ្លួន
គិតយូរមិនយល់ ម្តងខ្មែរម្តងយួន តែច្បាស់ក្នុងខ្លួន
ខ្ញុំជាខេមរា។

ខ្មែរក្រោមប្រឹងរស់ ពេលនេះមានឈ្មោះ សាយសព្វទិសា
មាននៅអាមេរិក ប្រទេសកាណាដា អូស្ត្រាលីសា
នូវែលហ្សីឡងដ៏។

បារាំងអ៊ីតាលី ខ្មែរមួយគ្មានពីរ ស្វីសនិងហូឡង់ដ៏
មានដិនម៉ាក ជប៉ុនថៃឡង់ដ៏ រួមដាយស្រោចស្រង់
ជួយជាតិបានខ្ពស់។

ខ្មែរអើយមូលមី រួបរួមសាមគ្គី ទាំងស្រីទាំងប្រុស
គិតប្រយោជន៍ជាតិ ឲ្យមានកេរ្តិ៍ឈ្មោះ ល្បីល្បាញខ្ពង់ខ្ពស់
ខ្មែររស់ក្នុងលោក។

ខ្មែរកុំភ្លេចខ្លួន មួយពាន់ប្រាំបួន រយសែសិបប្រាំ
បួននោះផងណា ថ្ងៃបួនមិថុនា ពួកយួនត្រួតត្រា
ខេមរាម្ចាស់ដី។

រៀបរៀងដោយ ហឿង សុវណ្ណ

ថ្ងៃសៅរ៍ ១៣កើត ខែជេស្ឋ ឆ្នាំរោងចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី0២ ខែមិថុនា គ.ស.២០១២